# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

## គម្រោងបញ្ចប់ផែនការ

## កំណែលើកទី ១៥

## ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧

**សេចក្តីសង្ខេប** .......... 2

I. **សេចក្តីផ្តើម** .......... 2

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 8

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 10

ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត .......... 11

ខ. អង្គបុរេជំនុំជម្រះ .......... 15

IV. **ផែនការបញ្ចប់សវនាការ** .......... 17

ក. សំណុំរឿង០០២/០២ .......... 18

ខ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 21

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 22

ក. សំណុំរឿង០០២/០២ .......... 22

ខ. សំណុំរឿង០០៣ និងសំណុំរឿង០០៤ .......... 22

VI. **សេចក្តីសន្និដ្ឋាន** .......... 22

ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**សំគាល់៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាល ដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះ") ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី១៥ នៃ គម្រោងបញ្ចប់ផែនការនេះដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

នៅក្នុងកំឡុងត្រីមាសនេះអង្គជំនុំជម្រះបានបន្តពិភាក្សាសម្រេចអំពីសាលក្រម និងធ្វើសេចក្តីព្រាងសាលក្រម។

នៅក្នុងកំឡុងពេលត្រីមាសនេះ សហចៅក្រមស៊ើបអង្កេតបាន ទទួលដីកាសន្និដ្ឋានស្ថាពរពីការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០៣ និងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង០០៤/០២។ ក្នុងសំណុំរឿង០០៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ទាក់ទិននឹងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ដែលរារាំងមិនឲ្យបញ្ជូនសំណុំរឿងនេះទៅសហព្រះរាជអាជ្ញាសុំសេចក្តីសន្និដ្ឋានស្ថាពរ។ មេធាវីការពារក្តីបានដាក់ញត្តិសុំមោឃភាព។

គម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពី ស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះវិសាមញ្ញ") បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការ

រំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩"[1]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី១៥ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[2]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣

៤ សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ កាំង ហ្គេចអ៊ាវ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្ដី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្ដន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្ដឹងសាទុក្ខកម្រិត ត្រឹមតែស្នើសុំសេចក្ដីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុត នៃសហឧក្រិដ្ឋកម្ម រួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល និងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្ដន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

---

ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្ដីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់និងការប្រព្រឹត្តលើពុទ្ធសាសនិក) ការដ្ឋានទំនប់ ១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និងការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍។ សវនាការលើភស្តុតាងចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការចំនួន២៧៤ថ្ងៃ និងស្តាប់សក្ខីកម្មសាក្សីចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន៨នាក់។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើទាមទារសំណងចុងក្រោយរបស់ខ្លួននៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ និងសេចក្តីសន្និដ្ឋានបន្ថែមលើបញ្ហាថវិកានៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។ បច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងពិភាក្សាសម្រេចអំពីសាលក្រមរបស់ខ្លួន និងធ្វើសេចក្តីព្រាងសាលក្រមដោយមានសំអាងហេតុ ដែលសាលក្រមនេះរំពឹងថានឹងចេញនៅត្រឹម ត្រីមាសទីពីរឆ្នាំ ២០១៨។

៧ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

៨ ស្ថានភាពនៃការស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ មានដូចខាងក្រោម៖

ក- នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះ ស្រាយដោយមានសម្អាងហេតុពេញលេញលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១។ ដីកាដំណោះស្រាយកំពុងស្ថិតក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

ខ- នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបានបញ្ជូន សំណុំរឿង០០៣ ទៅការិយាល័យសហព្រះរាជអាជ្ញាពិនិត្យដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានស្ថាពរនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងថានឹងចេញនៅត្រីមាសទី៣ ឆ្នាំ២០១៨។

គ- នៅថ្ងៃទី ១៨ និង ២១ ខែ សីហា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានទទួលដីកាសន្និដ្ឋានស្ថាពរចំនួនពីរក្នុងសំណុំរឿង០០៤/០២ពីសហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ។ នៅថ្ងៃទី៣០ ខែតុលា សហចៅក្រមស៊ើបអង្កេតបានទទួលចម្លើយតបរបស់មេធាវីការពារក្តី។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងថានឹងចេញនៅត្រីមាសទី២ ឆ្នាំ ២០១៨។

ឃ- នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ កិច្ចស៊ើបសួរ នៅក្នុង*សំណុំរឿង ០០៤* ត្រូវបានបញ្ចប់ជាលើកទី២ ក្រោយពីដោះស្រាយសំណើបន្ថែមជាច្រើនពីភាគី។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាក់ទិននឹងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមក្នុងសំណុំរឿង០០៤។ សំណុំរឿងនេះអាចបញ្ជូនទៅសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានស្ថាពរបានតែនៅពេលដែលមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ត្រូវចេញដោយអង្គបុរេជំនុំជម្រះប៉ុណ្ណោះ។ ដីកាដំណោះស្រាយនៅក្នុងរឿងក្តីនេះ រំពឹងថានឹងចេញនៅក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ ២០១៨។

៩ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញកំណត់ព្រឹត្តិការណ៍សំខាន់ចំនួន១០សម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី២ ឆ្នាំ២០១៨)។

(ii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៣ ឆ្នាំ២០១៨) និង

(iii) ចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមានបណ្តឹងសាទុក្ខ (ត្រីមាសទី១ ឆ្នាំ២០២០)។

១០ នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤ សំណុំរឿង០០៤/០១ និងសំណុំរឿង០០៤/០២ ព្រឹត្តិការណ៍ដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរ ដែលនៅសេសសល់ ហើយ ក្នុងករណីមានការចោទប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និង បណ្តឹងសាទុក្ខ[3]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(iv) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេច ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៨)។

(v) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០១៩) ។

(vi) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៨)។

(vii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៩)។

(viii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង០០៤/០១ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៨) ។

---

[3] ដីកាដំណោះស្រាយនឹងបញ្ជាក់ថានឹងមានការចោទប្រកាន់ឬទម្លាក់ការចោទប្រកាន់។ ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

(ix) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤/០២ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៨)។

(x) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០១៩)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការធានឆាប់រហ័ស

១១ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-១០១៧ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១២ ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាមហាសន្និបាតអង្គការ សហប្រជាជាតិក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេច កំណត់ទឹក ប្រាក់ចំនួនមិនលើសពី ០៨ លានដុល្លារ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អ.វ.ត.ក មិនឲ្យរអាក់រអួលក្នុងកំឡុង៤ខែដំបូងនៃឆ្នាំ២០១៨ ដោយបើកឱកាសឲ្យមានការរៃអង្គាស ថវិកាស្ម័គ្រ ចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់វិភាគទានដោយផ្ទាល់ ចំនួន៤,០លានដុល្លារដូចដែលបានធ្វើនៅក្នុងឆ្នាំ២០១៧ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ៦ ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ ២០១៨ គឺជាវិធានការដ៏សំខាន់

ដែលជួយដល់ ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃអ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំង នេះធានា ថា ដំណាក់កាលដែលមានទំហំការងារច្រើនបំផុត បច្ចុប្បន្ននៅក្នុងកិច្ចការរបស់ អ.វ.ត.ក បានបន្ត ទទួលបាននូវការយក ចិត្តទុកដាក់ជានិច្ច។ លើសពីនេះទៀត វិភាគទានស្ម័គ្រចិត្តតាមការប៉ាន់ ប្រមាណគឺ មានចំនួន ៩,២២លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ០,១៣៧ លានដុល្លារ សម្រាប់ភាគីជាតិ ដោយប្រៀបទៅនឹងគម្រោងថវិកាដែលបានអនុម័តរួចហើយចំនួន ១៨,៩៣ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ៥,៧៩លានដុល្លារសម្រាប់ភាគីជាតិក្នុងឆ្នាំ២០១៨។ ក្នុងតួលេខនេះ ភាគីអន្តរជាតិបានទទួលទឹកប្រាក់ចំនួន០,៤៨ លានដុល្លារមកដល់ពេលនេះ ហើយចំនួនតុល្យការរំពឹងថានឹងទទួលបាននៅកំឡុងឆ្នាំនេះ។

១៣ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តឧបត្ថមធនចំនួន១១លានដុល្លារដើម្បីបំពេញបន្ថែមទៅលើធនធានហិរញ្ញវត្ថុស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក សម្រាប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ វិភាគទានស្ម័គចិត្តដែលទទួលបានមានចំនួន ៩,៣៧ លានដុល្លារ សម្រាប់ធនធានសរុបដែលមាន ២០,៣៧ លានដុល្លារ។ ខ្ទង់ចំណាយស្តាពរសម្រាប់ឆ្នាំ២០១៧ គឺត្រូវបានប៉ាន់ស្មានថាស្ថិតនៅក្នុងរង្វង់ធនធានដែលមានខាងលើ។ នៅចុងឆ្នាំ២០១៧ ភាគីជាតិបានទទួលការគាំទ្រដោយផ្ទាល់ចំនួនទឹកប្រាក់៤,១៥លានដុល្លារពីរាជរដ្ឋាភិបាលកម្ពុជានិងវិភាគទានស្ម័គចិត្តចំនួន១,៧៣លានដុល្លារសម្រាប់ធនធាន ដែលមានសរុបចំនួន ៥,៨៨ លានដុល្លារ។ ខ្ទង់ចំណាយស្តាពរសម្រាប់ឆ្នាំ២០១៧គឺត្រូវបានប៉ាន់ប្រមាណថាមានចំនួនក្នុងរង្វង់ធនធានខាងលើ។

១៤ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោមត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថា កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនឹងមិនត្រូវរំខានដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើងម្តងទៀត យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៥ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរឬក៏កណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ តាម

ការចោទប្រកាន់[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាព នៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូន រឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[5]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូល នៅក្នុង សំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ការសម្រេចសេចក្តីចុងក្រោយនៃសំណុំរឿង ០០២/០២ នឹងបញ្ចប់នូវកិច្ចនីតិវិធីសំណុំរឿង០០២ តែម្តង។

១៦ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ បានជំរុញឱ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលលទ្ធផលពីធនធានមនុស្សរបស់ខ្លួន ជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីឥតសំណង និងកម្មសិក្សាការីបន្ថែមទៀតដែលបានកំណត់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានបង្កើនលទ្ធផលនៃកិច្ចស៊ើបសួរ។ ជាងនេះទៀត ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាបន្ថែមទៀត ដើម្បីគាំទ្រដល់ការិយាល័យតុលាការដើម្បីធានាសេវាបកប្រែនិងប្រតិចារឹកបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

---

[4] វិធាន៦៦ស្ទួន អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតដកចេញអង្គហេតុជាក់លាក់មួយចំនួនពីការស៊ើបអង្កេតដរាបណាអង្គ ហេតុដែលនៅសល់អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សេចក្តីសម្រេចប្រើវិធាន៦៦ស្ទួនគឺតម្រូវដោយច្បាប់ដែលនឹងធ្វើនៅដំណាក់កាលជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ។

[5] វិធាន៨៩*ស្ទួន៣*។

១៧ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើងក្រោយពីមានដីកាបញ្ជូនរឿងឱ្យស៊ើបសួរដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៩ ហើយក្រោយពីដាក់ សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយចំនួនទៀត សំណុំរឿង០០៤ក៏ត្រូវបំបែកទៅជាសំណុំរឿងចំនួន៣ ពោលគឺ៖ សំណុំរឿង០០៤/០១ ពាក់ព័ន្ធ អ៊ឹម ចែម សំណុំរឿង០០៤/០២ ពាក់ព័ន្ធ អោ អាន និង សំណុំរឿង០០៤ ប្រឆាំងនឹង យឹម ទិត្យ។ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) យុត្តាធិការរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្តឹងសាទុក្ខ។

## ក. <u>ការិយាល័យសហចៅក្រមស៊ើបអង្កេត</u>

១៨ ក្នុងកំឡុងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ មានការចុះបំពេញបេសកកម្មជាក់ស្តែងចំនួន ២៦៩លើក និងធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១៤១១នាក់។ កិច្ចស៊ើបសួរគ្រប់សំណុំរឿងទាំងអស់ត្រូវបានបញ្ចប់ហើយ។ ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង២៥០០នាក់ បច្ចុប្បន្នកំពុងស្ថិតក្រោមការពិនិត្យដើម្បីរៀបចំសេចក្តីសម្រេចទទួលស្គាល់ឬបដិសេធ។

១៩ នៅចុងបញ្ចប់នៃរយៈពេលធ្វើរបាយការណ៍នេះ ស្ថានភាពសំណុំរឿងមានដូចខាងក្រោម៖

ក. ក្នុងសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេត បានទទួលដីកាសន្និដ្ឋានស្ថាពរពី សហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អន្តរជាតិ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧។។ ចម្លើយតបរបស់មេធាវីការពារក្តីរំពឹងថានឹងដាក់នៅដើមត្រីមាសទី២ ចំណែកឯដីកាដំណោះស្រាយរំពឹងថានឹងចេញនៅត្រីមាសទី៣ ឆ្នាំ២០១៨។

ខ. ក្នុងសំណុំរឿង០០៤/០២ សហចៅក្រមស៊ើបអង្កេតបានទទួលចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងថា នឹងចេញនៅត្រីមាសទី២ឆ្នាំ២០១៨។

គ. ក្នុងសំណុំរឿង០០៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាក់ទិននឹងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧។ ដីកា

ដំណោះស្រាយអាចនឹងបញ្ជូនទៅសហព្រះរាជអាជ្ញាដើម្បីសន្និដ្ឋានស្ថាពរបានតែនៅពេលដែលសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះត្រូវបានចេញដោយអង្គបុរេជំនុំជម្រះ។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះគេរំពឹងថានឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៨។

២០ ក្នុងសំណុំរឿង០០៣ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដែលបានកែប្រែ ជាភាសាអង់គ្លេសនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានប្រមាណ៩៥០ទំព័រ។ នៅពេលដាក់សំណៅបកប្រែជាភាសាខ្មែរ ដែលរំពឹងថានឹងត្រូវការ៨សប្តាហ៍ មេធាវីការពារក្តីនឹងមានពេលចំនួន៨០ថ្ងៃក្នុងការឆ្លើយតប។ មេធាវីការពារក្តីត្រូវរំពឹងថានឹងដាក់ចម្លើយតបនៅខែមេសា ឆ្នាំ២០១៨ជាភាសាអង់គ្លេស ដែលសំណៅបកប្រែជាភាសាខ្មែរនឹងដាក់បន្ទាប់។ តាមការអនុវត្តនិងនីតិវិធីតុលាការ រយៈពេលធ្វើចម្លើយតបឬបណ្តឹងឧទ្ធរណ៍គឺចាប់ផ្តើមនៅពេលដែលមានការជូនដំណឹងអំពីសំណៅភាសាខ្មែរនៃឯកសារណាមួយ ។គួរចងចាំផងដែរថាសហចៅក្រមស៊ើបអង្កេតជាតិនិងក្រុមការងាររបស់លោកធ្វើការជាសំខាន់ទៅលើសំណៅភាសាខ្មែរនៃឯកសារណាមួយដែលបានដាក់។

២១ ក្នុងសំណុំរឿង០០៤/០២ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ត្រូវបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ និងជាភាសាខ្មែរ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

២២ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤បានបិទជាលើកទី២នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ក្រោយពីមានការដោះស្រាយសំណើបន្ថែមមួយចំនួនរបស់ភាគី។ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម។ តាមវិធាន៦៦(៤) បណ្តឹងឧទ្ធរណ៍នេះមិនអាចឲ្យចៅក្រមចេញដីកាបញ្ជូនរឿងទៅពិនិត្យដើម្បីសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានស្ថាពរបានទេរហូតដល់ពេលដែលអង្គបុរេជំនុំជម្រះបានសម្រេចទៅលើបណ្តឹងឧទ្ធរណ៍រួចរាល់។ ជាលទ្ធផល សេចក្តីសន្និដ្ឋានរបស់ភាគីមិនទំនងជានឹងដាក់នៅត្រីមាសទី៣ ឆ្នាំ២០១៨នោះទេ។ មេធាវីការពារក្តី បានដាក់ញត្តិស្នើសុំមោឃភាពមួយទៀតទៅសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧[6]។ បញ្ហាស្រដៀងគ្នានេះទាក់ទិននឹង

[6] នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ សហចៅក្រមអន្តរជាតិបានបញ្ជូនញត្តិស្នើសុំមោឃភាពដាក់ដោយមេធាវីការពារក្តី ជូនអង្គបុរេជំនុំជម្រះដើម្បីសម្រេច។

ពេលវេលាដែលចាំបាច់សម្រាប់ការបកប្រែក៏នឹងលេច ឡើងផងដែរក្នុងសំណុំរឿង០០៤ ដូចគ្នានឹងក្នុងសំណុំរឿង០០៣ផងដែរ។

២៣ ដំណើរការសំណុំរឿងទៅមុខនៃសំណុំរឿងទាំងនេះគឺនៅតែអាស្រ័យជាចម្បងទៅលើកត្តានានាដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅក្រម ជាពិសេស ថវិកាគ្រប់គ្រាន់ បុគ្គលិកគ្រប់គ្រាន់ ការជ្រើសរើសបុគ្គលិកទាន់ពេលវេលាសម្រាប់ តំណែងដែលទំនេរ និង ការបកប្រែឯកសារបានឆាប់រហ័ស។

២៤ បុគ្គលិកស្ទើរតែទាំងអស់មានពហុតួនាទីនៅក្នុងក្រុមការងារឬ ក្នុងផ្នែករដ្ឋបាល ទោះជាមានលក្ខណៈអចិន្ត្រៃយ៍ឬមិនអចិន្ត្រៃយ៍ក្តី។ចំនួនបុគ្គលិកមានកម្រិតនិងសមាសភាពរបស់បុគ្គលិក ធ្វើឲ្យការិយាល័យចៅក្រមស៊ើបអង្កេតងាយ ប្រឈមនឹងកង្វះបុគ្គលិក ទោះបីជាក្នុងករណីមានបុគ្គលិកមួយចំនួនតូចឈប់ពីការងារ ក៏ដោយ ដែល ជាហានិភ័យធ្ងន់ធ្ងរចំពោះកិច្ចការធានាការចងចាំការងារស្ថាប័ន។ ការចាកចេញរបស់បុគ្គលិកសំខាន់ៗ ដូចជា ដោយសារស្ថានភាពថវិកាទូទៅ ការជិតចប់អាណត្តិរបស់ការិយាល័យ ឬការរៀបចំផែនការអាជីព ដែលចំណុចទាំងនេះបង្ហាញពីហានិភ័យធ្ងន់ធ្ងរមួយទៀតចំពោះតារាងពេលវេលាដែលបានគ្រោងទុក។ បុគ្គលិកថ្មីនឹងត្រូវការពេលវេលាជាចាំបាច់ដើម្បីស្គាល់នីតិវិធីនិងភស្តុតាងដើម្បីធ្វើការលើសំណុំរឿងប្រកបដោយប្រសិទ្ធភាព ហើយប្រការនេះនឹងមានផលប៉ះពាល់មិនអាចចៀសរួចទៅលើការវិត្តនៃសំណុំរឿងនានា។

២៥ ការផ្តល់សេវាបកប្រែទាន់ពេលវេលានិងវត្តមាន របស់មន្ត្រីច្បាប់ដែលមានបទពិសោធន៍គឺពិតជាមានសារៈ សំខាន់យ៉ាងខ្លាំងនៅក្នុងដំណាក់កាលធ្វើសេចក្តីព្រាងនេះ។ នេះគឺជាបញ្ហាមួយរបស់តួអង្គទាំងអស់ នៅក្នុងដំណើរការនីតិវិធី។ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់យោបល់ជូនសហចៅក្រមថាដោយផ្អែកលើធនធានមានកម្រិតរបស់ខ្លួនគាត់នឹងមិនអាចដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនជាភាសាខ្មែរ និងអង់គ្លេស ក្នុងរយៈពេល៣ខែដែលកំណត់ ដោយវិធានផ្ទៃក្នុង។ ទន្ទឹមគ្នានេះដែរក៏មានការសម្តែងការ បារម្ភស្រដៀងគ្នាពីសំណាក់ក្រុមមេធាវី ការពារក្តី ពាក់ព័ន្ធនឹងចម្លើយតបរបស់ពួកគេទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថាការបារម្ភទាំងនោះគឺមានលក្ខណៈ ត្រឹមត្រូវហេតុដូច្នេះសហចៅក្រមក៏អនុញ្ញាតយល់ព្រមឲ្យដាក់ចម្លើយតបទៅតាមនីតិវិធីជាក់ស្តែង។

២៦ ជាងនេះទៀត រយៈពេលអតិបរមានៃដីកាសន្និដ្ឋានស្ថាពរ និងចម្លើយតប គឺមិនត្រូវបានធ្វើនិយតកម្មទៅតាមវិធាននៃផ្ទៃក្នុងឬសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារឡើយ។ ក្នុងករណីចាំបាច់បំផុត សហចៅក្រមស៊ើបអង្កេតអាចប្រើអំណាចឥស្សរចិត្តក្នុងការកំណត់ចំនួនទំព័រ។ ទន្ទឹមនឹងនេះការដាក់ ឯកសារទាំងនេះគឺជាទឡ្ហីករណ៍សំខាន់ៗដែលបង្ហាញដោយអយ្យការនិងមេធាវីការពារក្តីមុនពេលចេញដីកាដំណោះស្រាយ ដូច្នេះសហចៅក្រមស៊ើបអង្កេតមានទស្សនៈថាពួកគាត់នឹងមិនត្រូវបានជ្រៀតជ្រែកឡើយសូម្បីតែបន្តិច។

២៧ កង្វះធនធានគ្រប់គ្រាន់នឹងជះឥទ្ធិពលទៅលើការព្រាងដីកាដំណោះស្រាយក្នុងសំណុំរឿងទាំងអស់។ រយៈពេល និងពេលវេលាកំណត់សម្រាប់ដីកាសន្និដ្ឋានស្ថាពរនិងចម្លើយតប ក៏ដូចជាបញ្ហាបកប្រែ ដែលបានរៀបរាប់ខាងលើ គឺជាចំណុចដែលអាចនាំឱ្យមានការពន្យារពេលចំពោះគ្រោងការណ៍នានា[7]។

២៨ កត្តាទាំងឡាយដែលបានរៀបរាប់ខាងលើ ជាលទ្ធផលគឺនាំឱ្យចេញដីកាដំណោះស្រាយដូចខាងក្រោម។ តារាងកំណត់ពេលវេលានៅតែមិនអាចនិងមិនគួរចាត់ទុកជាអ្វីឱ្យលើសពីការព្យាករណ៍អាកាសធាតុនោះឡើយ។

ក. ក្នុងសំណុំរឿង០០៣ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨។

ខ. ក្នុងសំណុំរឿង០០៤ ក្នុងត្រីមាសទី៤ ឆ្នាំ ២០១៨។

ឃ. ក្នុងសំណុំរឿង០០៤/០២ ក្នុងត្រីមាសទី២ ឆ្នាំ២០១៨។

---

[7] ពេលវេលាធ្វើសេចក្តីព្រាងដីកាដំណោះស្រាយគឺប្រហែល៣ខែ គិតចាប់ពីពេលដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០១ និងប្រហែល៨ខែក្រោយពីចេញសេចក្តីសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០២ ដែលមានលក្ខណៈស្មុគស្មាញស្រដៀងគ្នាទៅនឹងសំណុំរឿង០០៤ ដែរ។ ប៉ុន្តែ ក្នុងសំណុំរឿង០០៤/០១ ដែលធំជាងសំណុំរឿង០០១ ប៉ុន្តែស្មុគស្មាញតិចជាងសំណុំរឿង០០៤ ការ ធ្វើសេចក្តីព្រាងសំអាងហេតុត្រង់ផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ត្រូវការពេលជិត៥ខែ។ សំណុំរឿង០០៤/០២ មានលក្ខណៈស្មុគស្មាញជាងសំណុំរឿង០០៤/០១ ប៉ុន្តែស្មុគស្មាញតិចជាងសំណុំរឿង០០៤។

## ខ. <u>អង្គបុរេជំនុំជម្រះ</u>

២៩ នៅឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានចេញសាលដីកាចំនួន ២២ ទៅលើបណ្តឹងឧទ្ធរណ៍ចំនួន ១៥ និងពាក្យសុំធ្វើមោឃភាពចំនួន ៧ ព្រមទាំងសេចក្តីសម្រេចបន្ទាន់បង្ខំដែលពាក់ព័ន្ធចំនួន ៨។ សាលដីកាចំនួន ៤ ត្រូវបានចេញ ចាប់តាំងពីមានការកែប្រែចុងក្រោយនៃផែនការបញ្ចប់ ហើយសាលដីកានីមួយៗត្រូវការពេលវេលាពី១ខែទៅ៣ខែក្រោយពីអង្គបុរេជំនុំជម្រះទទួលចាត់ការ។ ហេតុនេះ អង្គជំនុំជម្រះបានបង្កើនសកម្មភាពរបស់ខ្លួន បើប្រៀបធៀបជាមួយ ឆ្នាំ២០១៥ ដែលបានចេញសាលដីកាចំនួន ១៥ និង២០១៦ ដែលបានចេញសាលដីកាចំនួន១៩។

៣០ អង្គបុរេជំនុំជម្រះបើកសវនាការរួមគ្នាដំបូងនៅថ្ងៃទី១១និង១២ ខែធ្នូ ឆ្នាំ២០១៧ អនុលោមតាមវិធានផ្ទៃក្នុង៧៧(៣) ៧៧(៥) និង ៧៧(៦) ដើម្បីស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១។

៣១ នៅចុងបញ្ចប់នៃរយៈពេលធ្វើសេចក្តីរាយការណ៍នេះ អង្គបុរេជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ និងញត្តិស្នើសុំមោឃភាពចំនួន ៥ ដែលញត្តិស្នើសុំមោឃភាពចំនួន ១ ក្នុងចំណោមនោះត្រូវបានដាក់ចាប់តាំងពីមានការកែប្រែចុងក្រោយនៃផែនការបញ្ចប់មកម្ល៉េះ៖

ក. ក្នុងសំណុំរឿង០០៣ ញត្តិស្នើសុំមោឃភាពចំនួន ១។

ខ. នៅក្នុង*សំណុំរឿង ០០៤* បណ្តឹងឧទ្ធរណ៍ចំនួន ១ និង ញត្តិស្នើសុំមោឃភាពចំនួន ១។

គ. នៅក្នុង*សំណុំរឿង ០០៤/០១* បណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងអង្គសេចក្តីនៃដីកាដំណោះស្រាយ និង បណ្តឹងឧទ្ធរណ៍មួយពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់នៃបណ្តឹងឧទ្ធរណ៍នោះ។

៣២ អង្គជំនុំជម្រះរក្សាការតាំងចិត្តក្នុងការចេញសេចក្តីសម្រេចលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង០០៤ក្នុងពេលវេលាសមស្រប ដែលគ្រោងនឹងបញ្ចប់ក្នុងរយៈពេល៦ខែ អាស្រ័យលើលក្ខណៈនៃសេចក្តីសន្និដ្ឋាន បុគ្គលិក និងធនធានបកប្រែភាសាដែលមានកម្រិត ចាប់ពីពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបាន "ទទួលពេញលេញ" ពោលគឺ នៅពេលភាគីទាំងអស់បានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររួចរាល់ហើយ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង ០០៤/០១ ការ

ដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរទាំងអស់ទៅលើបណ្ដឹងឧទ្ធរណ៍ បានបញ្ចប់រួចហើយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ហើយត្រូវការពេល វេលាចំនួន៤ខែ គិតចាប់ពីពេលចេញសំអាងហេតុនៃដីកាដំណោះស្រាយ។ ហេតុនេះ ការប៉ាន់ស្មាននាពេលបច្ចុប្បន្ន មានដូចខាងក្រោម៖

ក. នៅក្នុង*សំណុំរឿង ០០៣* សាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានប៉ាន់ស្មានត្រឹមត្រីមាសទី២ ឆ្នាំ២០១៩។

ខ. នៅក្នុង*សំណុំរឿង ០០៤* សាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានប៉ាន់ស្មានត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩។

គ. នៅក្នុង*សំណុំរឿង ០០៤/០១* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាំងពីរត្រូវបានប៉ាន់ស្មានថា នឹងចេញត្រឹមត្រីមាសទី២ ឆ្នាំ២០១៨។

ឃ. នៅក្នុង*សំណុំរឿង ០០៤/០២* សាលដីការបស់អង្គបុរេជំនុំជម្រះទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានប៉ាន់ស្មានត្រឹមត្រីមាសទី១ ឆ្នាំ២០១៩។

៣៣ ការប៉ាន់ស្មានសម្រាប់បណ្ដឹងឧទ្ធរណ៍នានាដែលអាចមាន ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤/០២ និង សំណុំរឿង ០០៤ ផ្អែកលើតារាងពេលវេលារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងអាស្រ័យលើការចេញដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញ។

៣៤ រាល់ការប៉ាន់ស្មានទាំងអស់ក៏អាស្រ័យទៅលើពេលវេលាចាំបាច់សម្រាប់បណ្ដឹងឧទ្ធរណ៍ការទទួលបានបណ្ដឹងឧទ្ធរណ៍ពេញលេញ បុគ្គលិកដែលមាននៅក្នុងអង្គបុរេជំនុំជម្រះ និងការបកប្រែសេចក្ដីសន្និដ្ឋានរបស់ភាគីបានឆាប់រហ័ស និងសាលដីកាជាបីភាសារបស់តុលាការ។

៣៥ ចុងក្រោយ ប្រសិនបើមានការដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដីអំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះនឹងត្រូវបានពេលវេលាប្រហែល ៣ ខែ ដើម្បីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ទាំងនេះ ក្រោយពេលចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

## IV. ផែនការបញ្ចប់សវនាការ

៣៦ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និងការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

៣៧ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីនុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបានមុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយអង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាសម្រេច។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្រប នៅក្នុងសាលក្រមនោះ។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. <u>សំណុំរឿង០០២/០២</u>

៣៨ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្ដាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្ដាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្ចីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្ដាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្ដី។ សវនាការលើភស្តុតាងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្ដឹង រដ្ឋប្បវេណីសរុបចំនួន ៦៣ និង អ្នកជំនាញចំនួន៨នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើជនជាតិចាម) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្តិសុខអូរកន្សែង និងភ្នំក្រោល និងមន្ទីរសន្តិសុខស២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។ បទបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង តួនាទីរបស់ជនជាប់ចោទ។

៣៩ ដើម្បីរៀបចំការបិទដំណើរការនីតិវិធី អង្គជំនុំជម្រះបានធ្វើកិច្ចប្រជុំរៀបចំសវនាការនៅខែធ្នូ ឆ្នាំ២០១៦ ដើម្បី ស្ដាប់សារណាពាក់ព័ន្ធនឹងសារណាបញ្ចប់ការដេញដោល និងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលក្នុងចំណោមបញ្ហាដទៃៗទៀត។ដោយកត់សម្គាល់បញ្ហាចម្បងៗលើកឡើងដោយភាគី ជាពិសេសរយៈពេលវែងខុសពីធម្មតា និងភាពស្មុគស្មាញនៃរឿងក្ដី អង្គជំនុំជម្រះក៏កំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាសវនាការនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងការចាប់ផ្ដើមសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។ ក្រោយមក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីមានពេលវេលាបន្ថែមមួយសប្ដាហ៍ទៀត ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសារតែការពិនិត្យឡើងវិញលើប្រតិចារឹកសវនាការរបស់អង្គភាពប្រតិចារឹកកំពុងបន្តដំណើរការ ដែលប្រការនេះបានបង្កជាផលវិបាកដល់ភាគីក្នុងការពឹងផ្អែកទៅលើកំណត់ហេតុរបស់តុលាការ នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហេតុនេះ ការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានកំណត់ពេលឡើងវិញ និងបានធ្វើឡើងចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ

២០១៧។ បន្ទាប់ពីនោះមក អង្គជំនុំជម្រះបានផ្អាកសវនាការដើម្បីពិភាក្សាសម្រេច និងរៀបចំសាលក្រមនៅក្នុងរឿងក្ដីនេះ។

៤០ ការប៉ាន់ស្មានដំបូងទៅលើតម្រូវការពេលវេលាក្នុងការចេញសាលក្រមក្នុងសំណុំរឿង០០២/០២ គឺធ្វើឡើងមុនពេលចាប់ផ្ដើមការជំនុំជម្រះដោយផ្អែកលើបទពិសោធន៍សំណុំរឿង០០២/០១ ដោយពុំទាន់បានដឹងមានសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកជំនាញ ចំនួនប៉ុន្មាននាក់នឹងត្រូវផ្ដល់សក្ខីកម្ម។ ការប៉ាន់ស្មាននេះ ត្រូវបានកែសម្រួលឡើងវិញនៅក្នុងការកែសម្រួលលើកទី១២ នៃគម្រោងបញ្ចប់ផែនការ ដោយពិចារណាទៅលើការណ៍ដែលថាមានសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្នុងចំនួនទ្វេដងត្រូវបានស្ដាប់សក្ខីកម្មនៅក្នុង សំណុំរឿង ០០២/០២ លើសសំណុំរឿង០០២/០១ ដែរ ដែលជាការបង្កើតនូវមូលដ្ឋានភស្ដុតាងធំជាងមុនច្រើន សម្រាប់ការពិចារណា និងវិភាគនៅក្នុងពេលពិភាក្សាសម្រេច និងដំណើរការព្រាងសាលក្រម។

៤១ សមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំពេញទៅតាមតារាងពេលវេលាបច្ចុប្បន្ននេះ ដើម្បីចេញសាលក្រមនៅក្នុងរឿងក្ដីនេះ នឹងអាស្រ័យជាបឋមទៅលើអង្គជំនុំជម្រះ និងអង្គភាពគាំទ្រដទៃទៀតដែលនៅមានបុគ្គលិកពេញលេញ។ នៅក្នុងអំឡុងឆ្នាំ ២០១៦ ត្រីមាសទី១ ឆ្នាំ ២០១៧ និងត្រីមាសចុងក្រោយឆ្នាំ២០១៧ ការរៀបចំព្រាងសាលក្រមទទួលផលប៉ះពាល់ដោយការលាឈប់របស់បុគ្គលិកនៅក្នុងអង្គជំនុំជម្រះ។ អង្គជំនុំជម្រះកំពុងជួបប្រទះការភាពអូសបន្លាយជាប្រព័ន្ធក្នុងដំណើរការជ្រើសរើសបុគ្គលិកអង្គការសហប្រជាជាតិ។ ប្រការនេះអាចប៉ះពាល់ដល់សមត្ថភាពរបស់អង្គជំនុំជម្រះ ក្នុងការចេញសាលក្រមជាភាសាបារាំងស្របគ្នាជាមួយនឹងការព្យាករនានានៅក្នុងគម្រោងបញ្ចប់ផែនការ។ ការឈប់ពីការងាររបស់បុគ្គលិកអាចរំពឹងថានឹងកើតឡើងដោយសារស្ថានភាពហិរញ្ញវត្ថុមិនច្បាស់លាស់របស់សាលាក្ដី កិច្ចសន្យារយៈពេលខ្លី និង ការហៀបនឹងបញ្ចប់សាលក្រមសំណុំរឿង០០២/០២ ដែលកាន់តែបានជំរុញឲ្យបុគ្គលិកស្វែងរកការងាររយៈពេលវែងនិងមានភាពច្បាស់លាស់។

៤២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ប្រាប់ការិយាល័យរដ្ឋបាលពីមុនមកអំពីបញ្ហាពាក់ព័ន្ធនឹងការបញ្ចប់ការបកប្រែឲ្យបានទាន់ពេលវេលា ដែលអាចពន្យារពេលបន្ដទៀតក្នុងការចេញសាលក្រម។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្នុងខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្ដីបានលើកឡើងកត្តា ២ ថែមទៀត ដែលអាចជះឥទ្ធិពលលើរយៈពេលនៃការរៀបចំសាលក្រម ពោលគឺ ការពិនិត្យប្រតិចារឹកដែលកំពុងតែ

ធ្វើ និងការបកប្រែសាលដីកាអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង០០២/០១ ទៅជាភាសាបារាំង។ ការបកប្រែជាភាសាបារាំងចុងក្រោយនៃសេចក្ដីសម្រេចនេះដែលបានរំពឹងថានឹងបញ្ចប់នៅចុងខែកក្កដា ឆ្នាំ២០១៧ ត្រូវបានប្រមើលថានឹងបញ្ចប់រហូតដល់ចុងឆ្នាំ២០១៧[8]។ ទាក់ទិននឹងប្រតិចារឹកនៃការជំនុំជម្រះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ប្រតិចារឹកសវនាការដែលត្រឹមត្រូវ គឺជាមូលដ្ឋានសំខាន់សម្រាប់ការរៀបចំសាលក្រម ក៏ដូចជាការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីនានាដែរ។ ទោះបី មេធាវីការពារក្ដី នួន ជា បានស្នើឱ្យបញ្ចប់ការពិនិត្យប្រតិចារឹកមុនថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ដើម្បីឱ្យសារណាបញ្ចប់ការពិភាក្សាដេញដោលអាចឆ្លុះបញ្ចាំងពីព័ត៌មានត្រឹមត្រូវក៏ដោយ តែដំណើរការពិនិត្យប្រតិចារឹកត្រូវបានបញ្ចប់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ សម្រាប់ប្រតិចារឹកជាភាសាអង់គ្លេស ហើយប្រតិចារឹកផ្សេងទៀតជាភាសាខ្មែរ និងភាសាបារាំងនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧។

៤៣ ដោយផ្អែកលើតារាងពេលវេលានេះ និងនៅក្នុងចម្លើយតបទៅនឹងសំណើរបស់ភាគីអង្គជំនុំជម្រះបានអនុញ្ញាតឱ្យពន្យារពេល ១ សប្ដាហ៍ សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងបានកំណត់កាលបរិច្ឆេទសាជាថ្មីនូវការចាប់ផ្ដើមនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧។ ដំណើរការរៀបចំសេចក្ដីព្រាងសាលក្រមត្រូវបានធ្វើឱ្យមានភាពស្មុគស្មាញ ដោយសារភាពមិនច្បាស់លាស់ ពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវនៃកំណត់ហេតុសវនាការនាពេលនេះ និងពេលវេលាសមស្របក្នុងការពិនិត្យប្រតិចារឹកសវនាការ។ ដោយសារមានស្ថានភាពនេះ អង្គជំនុំជម្រះក៏បានយល់ស្របផងដែរតាមសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលស្នើសុំឱ្យភាគីដាក់ការកែតម្រូវទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន បន្ទាប់ពីការពិនិត្យបញ្ចប់ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី។ ការកែតម្រូវទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវបានដាក់ទៅតាមពេលវេលាកំណត់ចុងក្រោយគឺនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧។ នាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះបន្តវាយតម្លៃនូវផលប៉ះពាល់ដែលការកែប្រែដោយផ្អែកទៅលើការកែតម្រូវច្រើនទៅលើប្រតិចារឹកនោះ ដែលអាចមានចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះទៅលើភស្តុតាង។ ប្រការនេះ ហាក់ដូចជាមិន មានផលប៉ះពាល់ ទៅលើពេលវេលានៃការចេញសាលក្រមសំណុំរឿង ០០២/០២ ប៉ុន្តែដំណើរការវាយតម្លៃនៅតែធ្វើបន្តទៀតក្នុងបរិបទនៃការពិភាក្សាសម្រេច។

[8] ការបកប្រែភាសាបារាំងត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨។

៤៤ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅក្នុងអំឡុងពេលសវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា ការបកប្រែសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនទៅជាភាសាខ្មែរឲ្យបានពេញលេញមុនការចេញសាលក្រម គឺជាបញ្ហាសក្តានុពលនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងរឿងក្តីនេះ។ ប្រការនេះ បង្ហាញអំពីសារៈសំខាន់ក្នុងការរក្សាទុកបុគ្គលិកឲ្យបានគ្រប់គ្រាន់សម្រាប់កិច្ចការបកប្រែជូនអង្គជំនុំជម្រះ ដើម្បីអនុលោមទៅតាមកាលបរិច្ឆេទដែលបានកំណត់។ អង្គជំនុំជម្រះបានទទួលព័ត៌មានថា អាចរំពឹងថានឹងទទួលការបកប្រែផ្នែកខ្លះនៃអត្ថបទរបស់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនីមួយៗជាភាសាខ្មែរ ត្រឹមពាក់កណ្តាលខែកញ្ញា ហើយការបកប្រែជើងទំព័រនៃសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលជាភាសាខ្មែរត្រឹមខែធ្នូ ឆ្នាំ។

៤៥ អង្គជំនុំជម្រះសាលាដំបូងបន្តពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។ សម្បទារបស់ជនជាប់ចោទក្នុងការបន្តចូលរួមសវនាការត្រូវបានវាយតម្លៃនៅចុងខែកក្កដាឆ្នាំ២០១៦ ហើយពិនិត្យឃើញថាជន ជាប់ចោទទាំងពីរមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ របាយការណ៍វេជ្ជសាស្ត្រកត់សម្គាល់អំពីជំងឺមួយចំនួនដែលជនជាប់ចោទមាន ហើយបានផ្តល់អនុសាសន៍ឲ្យវាយតម្លៃទៅមុខងារសតិបញ្ញារបស់ជនជាប់ចោទរៀងរាល់ត្រីមាស។ ការវាយតម្លៃផ្នែកវេជ្ជសាស្ត្របែបនេះត្រូវបានគ្រោងសម្រាប់ត្រីមាសទី១ឆ្នាំ២០១៨។

៤៦ ដោយពិចារណាទៅលើកត្តាទាំងឡាយខាងលើនេះ អង្គជំនុំជម្រះសូមបន្តគោលដៅ ចេញសាលក្រមនៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៨។ ប៉ុន្តែ អង្គជំនុំជម្រះកត់សម្គាល់ថាបញ្ហានានា រួមទាំងហិរញ្ញវត្ថុអវតក បុគ្គលិករបស់អង្គជំនុំជម្រះ និង ការបកប្រែសាលក្រមទៅជាភាសាខ្មែរនិងភាសាបារាំង អាចតម្រូវឲ្យមានការពន្យារពេលរហូតដល់ត្រីមាសទី៣ឆ្នាំ២០១៨។

## ខ. <u>សំណុំរឿង០០៣ និង សំណុំរឿង០០៤</u>

៤៧ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ បើមិនដូច្នោះទេ យើងមិនអាចស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន

ឡើយ។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. <u>សំណុំរឿង០០២/០២</u>

៤៨ អង្គជំនុំជម្រះតុលាការកំពូលព្យាករណ៍នៅពេលនេះថា បណ្តឹងសាទុក្ខ (មួយឬច្រើន) ប្រសិនបើដាក់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ នឹងមានចំនួនតិចបំផុតដោយសារពេលវេលានិងធនធាន ដូចក្នុងសំណុំរឿង០០២/០១ ដែរ។ រហូតទាល់តែចេញសាលក្រមក្នុងសំណុំរឿង០០២/០២ ទើបមានលទ្ធភាពសម្រាប់ភាគីដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងនោះ ដែលត្រូវតែសម្រេចនៅក្នុងរយៈពេលបីខែ កំណត់ដោយច្បាប់ ពន្យារពេលបួនខែក្នុងករណីពិសេស។

### ខ. <u>សំណុំរឿង០០៣ និងសំណុំរឿង០០៤</u>

៤៩ ប្រសិនបើសំណុំរឿង០០៣ និង/ឬ ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងឧទ្ធរណ៍ភ្លាមៗឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្តឹងសាទុក្ខណានៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

៥០ សម្រាប់ឆ្នាំ២០១៨ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួនពីរក្នុងសំណុំរឿង០០២/០២ គឺ (i) ការចេញសាលក្រម និង (ii) ពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ដែលអាចមានប្រឆាំងនឹងសាលក្រម។ ចំពោះសំណុំរឿង ០០៣, ០០៤/០១, ០០៤/០២ និង ០០៤ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួន៤ គឺ (i) ការចេញដីកាដំណោះស្រាយសម្រាប់សំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់

កិច្ចនីតិវិធី, (ii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី, (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី និងការសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ដែលអាចមាន ប្រឆាំងទៅនឹងដីកាដំណោះស្រាយទាំងនោះ ក្នុង (iv) សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម ដោយមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៥១ នៅឆ្នាំ២០១៩ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួន៣ គឺការចេញសេចក្តីសម្រេចទៅបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ នៅក្នុង (i) សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន (ii) សំណុំរឿង ០០៣ ពាក់ព័ន្ធនឹង មាស មុត និង សំណុំរឿង០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ ជាមួយនឹងសេចក្តីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៥២ នៅឆ្នាំ២០២០ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់មួយ គឺ (i) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២។

៥៣ ក្នុងករណីដែលសំណុំរឿង០០៣ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករនៅពេលនោះ។

៥៤ ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករ មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ១៥ - ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧




(ង) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០២

(ច) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០១, ០០៤/០២

(ឆ) សំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ចេញនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

(ជ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤